ភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣

# សេចក្តីសំរេចលេខ ០៧ សសរ ស្តីពីការបង្កើត

## « គណៈកម្មាធិការជាតិវិនិយោគ »

*********

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃ កម្ពុជា របស់ សម្តេចព្រះឧបយុវរាជនរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ។
- យោងសេចក្តីសំរេចចិត្តរបស់សភាតំណាងរាស្ត្រទាំង ១២០ រូប ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតំកល់ទុកនូវច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ក្នុងនោះមានច្បាប់ ស្តីពីការវិនិយោគ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៨ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ និងក្រឹត្យលេខ ៩២ ក្រ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩២ ។
- បានឃើញតំរូវការចាំបាច់ នៃការងារវិនិយោគនៅកម្ពុជា

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មាធិការជាតិមួយឈ្មោះថា " គណៈកម្មាធិការជាតិវិនិយោគ " ដែលមានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១- ឯកឧត្តម ធាត ឈន់ | ឧបនាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្តម វ៉េង សិរីវុឌ្ឍ | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ព្រះអង្គម្ចាស់នរោត្តម សិរីវុឌ្ឍ | រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥- ឯកឧត្តម ជា ចាន់តូ | រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៦- ឯកឧត្តម វ៉ារ ហួត | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- ឯកឧត្តម សម រង្ស៊ី | រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម ពូ សុធីរៈ | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម | សមាជិក |

៩- ឯកឧត្តម ប៉ែន ធុល តំណាងរាស្ត្រ — សមាជិក

១០- ឯកឧត្តម ហេង វង្សប៊ុនឆាត អនុរដ្ឋមន្ត្រីក្រសួងឧត្តមសិក្សា — សមាជិក

១១ - លោកជំទាវ ជូឡុង សូមូរ៉ាអគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា — សមាជិក

- លោក សារ៉ាត់ ខាន់ និង លោក អ៊ុង គាស៊ាម — អ្នករាយការណ៍

ប្រការ ២ : គណៈកម្មាធិការជាតិវិនិយោគ មានសិទ្ធិអញ្ជើញ ឯកឧត្តម អស់លោក រដ្ឋមន្ត្រីឬ តំណាងស្ថាប័នដទៃទៀតដែលមានការពាក់ព័ន្ធទៅនឹងគំរោងវិនិយោគនីមួយ ៗ ដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនអោយមក ចូលរួមពិភាក្សានិងសំរេចតាមករណីជាក់ស្តែង ។

ប្រការ ៣ : គណៈកម្មាធិការជាតិវិនិយោគមានភារកិច្ចដូចតទៅ ÷

១- បន្តរៀបចំ ប្រមូលផ្តុំ និង ចងក្រងឯកសារច្បាប់ និង បទបញ្ញត្តិទាំងឡាយដែលទាក់ទងនឹង វិនិយោគ អោយកាន់តែមានប្រសិទ្ធភាព សំរាប់ផ្សព្វផ្សាយដល់វិនិយោគ ជាតិ និង អន្តរជាតិ ។

២- រៀបចំរបៀបរបបធ្វើការងារតាមប្រព័ន្ធ " ច្រកចេញ- ចូលតែមួយ " ដើម្បីសំរួលកិច្ចការរបស់អ្នកវិនិយោគ ។

៣- ជួយចង្កុលគួណៈងាយស្រួល និង ផ្តល់ព័ត៌មានដល់អ្នកវិនិយោគ អំពីវិស័យផ្សេងៗ ដែលអាចធ្វើវិនិយោគ អំពីអង្គភាពនានានៃប្រទេសកម្ពុជា ដែលត្រូវធ្វើទំនាក់ទំនង និង អំពីច្បាប់វិនិយោគ អំពីរបៀបរបបដែលត្រូវធ្វើ និង ព័ត៌មានផ្សេង ៗ ទៀតដែលចាំបាច់ ។ ជួយផ្តល់មតិ ដល់ក្រសួង- ខេត្ត និង ក្រុងដើម្បីសហការបានល្អជាមួយ អ្នកវិនិយោគ ។

៤- ទទួលបន្ទុកសំរបសំរួលរវាងអ្នកវិនិយោគ ជាមួយបណ្តាក្រសួង ខេត្ត និង ក្រុង ក្នុងការដោះស្រាយបញ្ហាផ្សេងៗ ដែលទាក់ទងនឹងការងារវិនិយោគ ។

៥- ណែនាំអោយអ្នកវិនិយោគរៀបចំឯកសារចាំបាច់ទាំងឡាយដូចតទៅ ÷

- ការសិក្សា អំពីសមិទ្ធិលទ្ធភាព
- របាយការណ៍សេដ្ឋកិច្ច - បច្ចេកទេស
- តម្លៃទូទាត់បច្ចុប្បន្នជាក់ស្តែង
- អត្រាចំណេញជាមូលដ្ឋាន
- រយៈពេលនៃការវិនិយោគ
- តម្លៃដែលសង្គមជាតិត្រូវទទួល
- តម្លៃដែលសង្គមជាតិត្រូវចំណាយ

៦-ពិនិត្យ និងសំរេចរាល់សំណើវិនិយោគរបស់បុគ្គល ឬ ក្រុមហ៊ុនឯកជន និង ក្រៅប្រទេសចំពោះកិច្ចសន្យា ការសុំបង្កើតក្រុមហ៊ុនវិនិយោគ ឬ សាខា ឬការិយាល័យ តំណាងក្រុមហ៊ុនវិនិយោគនានា ។ ចំពោះរាល់សំណើដែល មានលក្ខណៈស្មុគស្មាញ ត្រូវពិនិត្យ និងសុំយោបល់សំរេចពី សហប្រធាន នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្ន កម្ពុជា ។

៧-ចេញលិខិតអនុញ្ញាតអោយវិនិយោគតាមករណីនីមួយ ៗ ដល់អ្នកវិនិយោគក្នុង និង ក្រៅប្រទេស ។

៨-ចាត់តាំងតំណាងដើម្បីចូលរួម និង រៀបចំកិច្ចសន្យាវិនិយោគរវាងអ្នកវិនិយោគជាមួយក្រសួង ខេត្ត និង ក្រុង ដែលមានពាក់ព័ន្ធ ។

៩-តាមដាន និង ត្រួតពិនិត្យការអនុវត្តច្បាប់ និង បទបញ្ញត្តិផ្សេងៗ ទៀតដែល ទាក់ទងទៅនឹង ការងារវិនិយោគ និង ការអនុវត្តកិច្ចសន្យាវិនិយោគនានា ។

១០-ធ្វើរបាយការណ៍បូកសរុបសភាពការណ៍អនុវត្តការងារ វិនិយោគលើគ្រប់វិស័យជូន គណៈរដ្ឋមន្ត្រីតាមកាលកំណត់ ។

ប្រការ ៤ : សមាជិកទាំងអស់ នៃគណៈកម្មាធិការនេះ ត្រូវរួមធ្វើការងារតាមសេចក្តីអញ្ជើញ និងការ ណែនាំរបស់ប្រធាន ។

ប្រការ ៥ : ប្រធានគណៈកម្មាធិការជាតិវិនិយោគត្រូវរៀបចំលេខាធិការដ្ឋានមួយជាជំនួយការអចិន្ត្រៃយ៍ដែលមានទីតាំងនៅក្រសួងផែនការ ។

ប្រការ ៦ : គណៈកម្មាធិការជាតិវិនិយោគ មានសិទ្ធិប្រើប្រាស់ ត្រាដោយឡែក ។

ប្រការ៧ : ឧបនាយករដ្ឋមន្ត្រី ដែលមានការពាក់ព័ន្ធ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧត្តមសិក្សារដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន អោយបានសំរេចលទ្ធផលល្អ ។

ប្រការ ៨ : សេចក្តីសំរេចណា ដែលមានខ្លឹមសារផ្ទុយ និង សេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

សេចក្តីសំរេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ហត្ថលេខា តទៅ ។

**សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា**

ព្រះហស្តលេខា ហត្ថលេខា

**ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**